ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

KINGDOM OF CAMBODIA
Nation Religion King

ក្រសួងផែនការ
Ministry of Planning







# កម្មវិធីជាតិអត្តសញ្ញាណកម្មគ្រួសារក្រីក្រ
# The National Identification of Poor Households Programme

"គន្លឹះសំខាន់ដើម្បីគាំទ្រការអភិវឌ្ឍឱ្យមានសមធម៌
a Key Tool to Support Equitable Development"



# សាវតា

នៅកម្ពុជា ក្នុងរយៈពេលកន្លងមករហូតដល់បច្ចុប្បន្ន ផែនការកាត់បន្ថយភាពក្រីក្រ និងការផ្តល់សេវាជាទូទៅមិនសូវបានផ្តោតការយកចិត្តទុកដាក់ពេញលេញលើការផ្តល់ជំនួយដល់គ្រួសារក្រីក្រទេ។ ស្ថាប័នរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល បានបង្កើតនិងកំពុងប្រើប្រាស់នីតិវិធីខុសៗគ្នា ដើម្បីកំណត់អត្តសញ្ញាណគ្រួសារដែលត្រូវទទួលផលប្រយោជន៍។ លទ្ធផលពីការវិនិច្ឆ័យទាំងនោះ មិនអាចយកមកប្រៀបធៀបគ្នាបាន ហើយជាទូទៅមិនត្រូវបានផ្តល់ដល់អង្គការឬស្ថាប័នដទៃទៀតឡើយ។

ក្នុងវេទិកាជាតិ ដែលរៀបចំដោយក្រសួងផែនការ នាខែកុម្ភៈឆ្នាំ២០០៥ មានការឯកភាពគ្នាយ៉ាងទូលំទូលាយស្តីពីភាពចាំបាច់ ក្នុងការបង្កើតឱ្យមាននីតិវិធីស្តង់ដាររួមមួយ សម្រាប់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដែលអាចកាត់បន្ថយចំណាយក្នុងការកំណត់ក្រុមគោលដៅ និងធ្វើឱ្យមានប្រសិទ្ធភាពក្នុងការបែងចែកធនធានដ៏មានកម្រិត ដល់គ្រួសារក្រីក្រ ដែលកំពុងត្រូវការជំនួយ។ ក្រុមការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ត្រូវបានបង្កើតឡើងនៅខែមិថុនា ឆ្នាំ២០០៥ ហើយត្រូវបានដឹកនាំដោយក្រសួងផែនការ និងមានការគាំទ្របច្ចេកទេស ដោយកិច្ចសហ-ប្រតិបត្តិការបច្ចេកទេសអាល្លឺម៉ង់ (GTZ)។ ក្រុមការងារនេះ មានសមាសភាពតំណាងមកពីក្រសួងពាក់ព័ន្ធដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ។ ក្រុមការងារស្នូលត្រូវបានបង្កើតឡើង ហើយក្នុងឆ្នាំ២០០៥-២០០៦ បានបង្កើតនូវនីតិវិធី និងលក្ខណៈវិនិច្ឆ័យជាទម្រង់បញ្ជីសំណួរ សម្រាប់ការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រនៅ**តំបន់ជនបទ**។

ដើម្បីទទួលបាននូវជំនួយ ដើម្បីរៀបចំ និងអនុវត្តឧបករណ៍ស្តង់ដារសម្រាប់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ក្រសួងផែនការបានស្នើរដ្ឋាភិបាលសហព័ន្ធអាល្លឺម៉ង់ សុំការគាំទ្របន្ថែមលើផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស។ ជាលទ្ធផល នៅដើមឆ្នាំ២០០៦ រដ្ឋាភិបាលអាល្លឺម៉ង់បានធ្វើកិច្ចសន្យាជាមួយអង្គការ GTZ ដើម្បីគាំទ្រក្រសួងផែនការតាមរយៈកម្មវិធី "ការគាំទ្រដល់កម្មវិធីអត្តសញ្ញាណកម្ម-គ្រួសារក្រីក្រ" (IDPoor)។

# Background

In Cambodia until recently, poverty-oriented development planning and service provision has not focused enough attention on targeting assistance to poor people. Where household targeting has been implemented, each institution has developed and applied its own procedures and criteria for identifying beneficiaries. This means that results are not comparable with each other, and are generally also not shared with other organisations and institutions.

At a National Forum organised by the Ministry of Planning (MOP) in February 2005, there was broad consensus on the necessity to develop standardised national procedures for identification of poor households, in order to reduce the overall administrative costs of selecting target groups and to allow more efficient distribution of scarce development resources to those who need them most. A national Working Group on Identification of Poor Households, chaired by the MOP and with technical support from the German Government through German Technical Cooperation (GTZ), was established in June 2005. This working Group consists of relevant ministries, development partners and local and international NGOs. A smaller Core Group worked in 2005 and 2006 in a consultative process to develop initial procedures and standard criteria in the form of a questionnaire for conducting poor household identification in rural areas.

In order to secure mid-term assistance to introduce a standardised tool, the MOP approached the German Government for additional financial and technical support. This was granted and the German Government in early 2006 commissioned GTZ to assist the MOP through the programme "Support to Identification of Poor Households Programme" (IDPoor).



## គោលបំណង

គោលបំណងរួមរបស់កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រក្រសួងផែនការ គឺប្រកាសទទួលស្គាល់ជាផ្លូវការដោយរាជរដ្ឋាភិបាលកម្ពុជា នូវនីតិវិធីស្តង់ដារជាតិនេះ សម្រាប់កំណត់អត្តសញ្ញាណគ្រួសារក្រីក្រ និងបង្កើនការអនុវត្តឱ្យបានទូលំទូលាយក្នុងប្រទេសកម្ពុជា។ កម្មវិធីនេះ មានគោលបំណងសំខាន់មួយទៀតគឺដើម្បីជំរុញឱ្យមានការប្រើប្រាស់ទូលំទូលាយនូវទិន្នន័យ ដោយស្ថាប័នរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងគម្រោងនិងកម្មវិធីតាមវិស័យនានា ក៏ដូចជាក្រុមប្រឹក្សាឃុំ ដើម្បីធ្វើជាឧបករណ៍សម្រាប់ការផ្តល់សេវា និងជំនួយដល់គ្រួសារក្រីក្រ ។

## Objectives

The overall objective of the MOP Identification of Poor Households Programme is to officially mandate national standardised Procedures for Identification of Poor Households and to achieve their increasing implementation throughout Cambodia.

Another key objective of the Programme is to promote widespread use of the collected data by government institutions, non-governmental organisations, and sector programmes and projects, as well as Commune Councils, as a tool for targeting services and assistance to poor households.

## តើអ្វីទៅជាអត្តសញ្ញាណកម្មគ្រួសារក្រីក្រ? តើដើម្បីអ្វី?

យោងទៅលើនីតិវិធីដែលប្រើដោយក្រសួងផែនការ និងអង្គការដៃគូ អត្តសញ្ញាណកម្មគ្រួសារក្រីក្រ គឺជាការរកឱ្យឃើញ គ្រួសារក្រីក្រ និងកម្រិតភាពក្រីក្ររបស់គ្រួសារនីមួយៗដែលរស់នៅតំបន់ជនបទ។ គោលបំណងនៃការកំណត់អត្ត-សញ្ញាណគ្រួសារនីមួយៗ គឺដើម្បីផ្តល់សេវា និងជំនួយដល់គ្រួសារក្រីក្រដោយផ្ទាល់ ដើម្បីជួយពួកគាត់ឱ្យចាកផុតពីភាពក្រីក្រ និងការពារពួកគាត់ពីវិបត្តិថៃដន្យផ្សេងៗ (ដូចជា ជម្ងឺធ្ងន់ធ្ងរ ខូចខាតផលដំណាំ) ដែលអាចនាំពួកគាត់ឱ្យធ្លាក់កាន់តែជ្រៅក្នុងភាពក្រីក្រ ។

ទិន្នន័យដែលបានមកពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ អាចប្រើប្រាស់បានសម្រាប់គណនាប្រៀបធៀបកម្រិតភាពក្រីក្រនៃភូមិនីមួយៗ។ អ្នកផ្តល់សេវាអាចប្រើប្រាស់ទិន្នន័យនេះ ដើម្បីកំណត់ឃុំឬភូមិក្រីក្រ និងគ្រួសារក្រីក្រនៅក្នុងតំបន់ ។

## What is Identification of Poor Households? Why do we need it?

Identification of poor households, according to the procedures used by the Ministry of Planning and partner organisations, is a participatory and consultative process carried out by villagers in rural areas that determines which households are poor and the poverty level of these individual households in villages. The data is also used for calculating comparative poverty levels of villages.

The purpose of identification of individual households is to provide data to decision-makers and service providers to enable them to directly target services and development assistance to poor households in order to help lift these households out of poverty and to protect them from shocks (e.g. serious illness, crop failure) which may deepen their poverty. This data is also used for geographical targeting of services and assistance to poorer communes or villages.



នៅកម្ពុជា មានសក្តានុពលខ្ពស់នៃការប្រើប្រាស់ទិន្នន័យគ្រួសារក្រីក្រ សម្រាប់ការផ្តល់សេវាសុខភាពឥតបង់ថ្លៃឬចុះថ្លៃ (ដូចជា តាមរយៈមូលនិធិសមធម៌សុខភាពឬការធានារ៉ាប់រងផ្នែកសុខភាពសង្គម) អាហារូបករណ៍ ឬជំនួយហិរញ្ញវត្ថុសម្រាប់សិស្សឬនិស្សិតក្រីក្រ សេវាអភិវឌ្ឍន៍ជនបទ និងវិស័យកសិកម្ម ការបែងចែកដីសម្បទានសង្គមកិច្ចដល់គ្រួសារក្រីក្រ និងអាចប្រើប្រាស់ក្នុងគោលដៅផ្សេងៗ។ ទិន្នន័យនេះក៏មានសក្តានុពលសម្រាប់ប្រើប្រាស់ក្នុងកម្មវិធីផ្តល់ប្រាក់ទ្រទ្រង់សុខមាលភាពសង្គមទាំងគ្មានល័ក្ខខ័ណ្ឌ និងមានល័ក្ខខ័ណ្ឌ។

In Cambodia there are many uses for data on poor households, such as the provision of free or discounted medical services (e.g. through Health Equity Funds or Social Health Insurance), scholarships or other financial support to poor school pupils and students, rural development and agriculture-related services and inputs, allocation of social concession land to the poor, and many other uses. There is also potential for developing conditional or unconditional cash transfer programmes.

## តំបន់គ្របដណ្តប់ដោយអត្តសញ្ញាណកម្មគ្រួសារក្រីក្រ

រហូតដល់ខែកក្កដា ឆ្នាំ២០០៨ អត្តសញ្ញាណកម្មគ្រួសារក្រីក្រដែលប្រើនីតិវិធីស្តង់ដារថ្នាក់ជាតិរបស់ក្រសួងផែនការ ត្រូវបានអនុវត្តនៅក្នុងខេត្តចំនួនប្រាំ (ខេត្តខ្លះត្រូវបានគ្របដណ្តប់មួយផ្នែក និងខ្លះទៀតគ្របដណ្តប់ទូទាំងខេត្ត) ស្មើនឹង **២១២៨ ភូមិ**។ ក្រសួងផែនការ កំពុងបន្តពង្រីកអត្តសញ្ញាណកម្មទៅខេត្តផ្សេងទៀត តាមលទ្ធភាព និងធនធានដែលមាន។ ក្នុងឆ្នាំ២០០៩ ក្រសួងផែនការ គ្រោងធ្វើអត្តសញ្ញាណកម្មយ៉ាងតិចប្រាំខេត្តទៀត ដែលខេត្តខ្លះត្រូវបានគ្របដណ្តប់មួយផ្នែក និងខ្លះទៀតគ្របដណ្តប់ ទូទាំងខេត្ត។

ក្រៅពីខេត្តដែលគ្របដណ្តប់មួយផ្នែក និងទាំងស្រុងដោយក្រសួងផែនការ ប្រតិបត្តិករមូលនិធិសមធម៌សុខភាព និងដៃគូរបស់ខ្លួន បានកំពុងប្រើប្រាស់នីតិវិធីស្តង់ដារជាតិ ដើម្បីការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រនៅក្នុងខេត្ត និងស្រុកមួយចំនួនទៀត។ តំបន់ក្នុង អង្គការដៃគូអាចនឹងគ្របដណ្តប់តំបន់ផ្សេងទៀត ក្នុងពេលអនាគត។

ក្រសួងផែនការ និងអង្គការដៃគូ បាននិងកំពុងគ្របដណ្តប់ និងគ្រោងគ្របដណ្តប់តំបន់ផ្សេងៗទៀត ឱ្យបានមួយផ្នែកធំនៃប្រទេសកម្ពុជា។ ដូច្នេះ មូលនិធិរយៈពេលវែង គឺត្រូវការជាចាំបាច់ ដើម្បីពង្រីកតំបន់គ្របដណ្តប់ និងបច្ចុប្បន្នភាពទិន្នន័យជាប្រចាំ។

## Where is Identification of Poor Households being conducted?

As of October 2008, identification of poor households using the national Procedures implemented by the MOP had been partially or fully conducted in a total of five provinces, and around **2128 villages**. The MOP is continuously expanding the coverage area as resources become available. In 2009 the MOP plans to fully or partially cover at least five more provinces.

In addition to the provinces partially or fully covered by the MOP, Health Equity Fund Operators have been using the Procedures for Identification of Poor Households in many other provinces and districts. These partners are also continuously expanding their coverage to other areas.

The MOP and its partners have therefore already covered, or plan to cover soon, a large part of the country. However, long-term funding is needed to enable systematic coverage and regular updates of the data.



សម្រាប់ព័ត៌មានលម្អិតអំពីតំបន់គ្របដណ្តប់ សូមមើលវែបសាយរបស់កម្មវិធី www.mop.gov.kh/ProgramsProjects/IDPoor/tabid/154/Default.aspx ឬ ធ្វើទំនាក់ទំនងជាមួយមន្ត្រីកម្មវិធី។

For up-to-date details about coverage areas, please refer to the programme webpage www.mop.gov.kh/ProgramsProjects/IDPoor/tabid/154/Default.aspx or contact the IDPoor Programme team.

## តើអត្តសញ្ញាណកម្មគ្រួសារក្រីក្រមានដំណើរការយ៉ាងដូចម្តេច?

អត្តសញ្ញាណកម្មគ្រួសារក្រីក្រក្នុងភូមិនីមួយៗ ត្រូវបានអនុវត្តដោយក្រុមតំណាងភូមិដោយមានការគាំទ្រ និងដឹកនាំដោយក្រុមតំណាងគណៈកម្មាធិការកសាងផែនការនិងថវិកា ក្រុមប្រឹក្សាឃុំ និងក្រុមសម្របសម្រួលថ្នាក់ខេត្តនិងស្រុក។ ដំណើរការអត្តសញ្ញាណកម្មគ្រួសារក្រីក្រក្នុងខេត្តនីមួយៗ ត្រូវបានសម្របសម្រួលដោយមន្ទីរផែនការខេត្ត សហការជាមួយអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត។ ក្រសួងផែនការផ្តល់ការបណ្តុះបណ្តាលនៅថ្នាក់ខេត្ត តាមដានការអនុវត្ត និងផ្តល់ការគាំទ្រផ្នែកបច្ចេកទេស។

ការអនុវត្តនីតិវិធី គឺផ្អែកលើវិធីសាស្ត្របណ្តុះបណ្តាលតាមលំដាប់។ មន្ត្រីក្រសួងផែនការ បណ្តុះបណ្តាលដល់សមាជិកក្រុមសម្របសម្រួលថ្នាក់ខេត្តនិងស្រុក និងគាំទ្រពួកគាត់ឱ្យមានសមត្ថភាព ដើម្បីឱ្យបណ្តុះ-បណ្តាលបន្តដល់ក្រុមប្រឹក្សាឃុំ សមាជិកក្រុមតំណាងគណៈកម្មាធិការកសាងផែនការនិងថវិកា សមាជិកក្រុមតំណាងភូមិ និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីដំណើរការអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។

ដំណើរការអត្តសញ្ញាណកម្មគ្រួសារក្រីក្រមាន ៧ ជំហាន។ ជំហានទាំងនេះ មានពិពណ៌នាលម្អិតនៅក្នុង *សៀវភៅណែនាំស្តីពីនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅកម្ពុជា* (អាចរកបាននៅលើវែបសាយរបស់កម្មវិធី)។ ជំហានទាំង៧ ត្រូវបានសង្ខេបដូចខាងក្រោម :

## How is Identification of Poor Households conducted?

The identification process in each village is carried out by a Village Representative Group (VRG), with the support and supervision of a Planning and Budgeting Committee Representative Group (PBCRG), the Commune Council, and Provincial and District Facilitation Teams (PFTs and DFTs). The whole process in a province is coordinated by the Provincial Department of Planning, in cooperation with the Provincial Local Administration Unit. The Ministry of Planning provides training at the provincial level, monitors implementation and gives ongoing technical support.

Implementation of the process depends on a cascade training approach. National-level Ministry staff train PFTs and DFTs as trainers and provide support to enable them to train Commune Councils, Planning and Budgeting Committee Representative Groups, Village Representative Groups and other stakeholders to implement the process for identification of poor households.

The process for identification of poor households consists of seven steps. These are described in detail in the document *Procedures for Identification of Poor Households in Cambodia* (please see the programme webpage). These steps are summarised in the box below.



**ជំហាន ១ :** ការជ្រើសរើស និងបណ្តុះបណ្តាលក្រុមតំណាងគណៈកម្មាធិការកសាងផែនការនិងថវិកា ( ក្រុមតំណាងគ.ផ.ថ)

**ជំហាន ២ :** ជ្រើសរើស និងបណ្តុះបណ្តាលក្រុមតំណាងភូមិ

**ជំហាន ៣ :** ក្រុមតំណាងភូមិ ចងក្រងបញ្ជីគ្រួសារក្នុងភូមិសម្ភាសន៍គ្រួសារ និងចងក្រងបញ្ជីព្រាងគ្រួសារក្រីក្រលើកដំបូង

**ជំហាន ៤ :** រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ក្នុងភូមិស្តីពីបញ្ជីព្រាងគ្រួសារក្រីក្រលើកដំបូង ការទទួលមតិជំទាស់របស់អ្នកភូមិ និងការរៀបចំបញ្ជីព្រាងគ្រួសារក្រីក្រចុងក្រោយ

**ជំហាន ៥ :** ការត្រួតពិនិត្យឡើងវិញ និងអនុម័តបញ្ជីគ្រួសារក្រីក្រចុងក្រោយ ដោយក្រុមប្រឹក្សាឃុំ និងការចែកចាយប័ណ្ណសមធម៌

**ជំហាន ៦ :** មន្ទីរផែនការខេត្ត បញ្ចូលទិន្នន័យទាំងអស់ និងរូបថតគ្រួសារក្រីក្រ ចូលក្នុងទិន្នន័យមូលដ្ឋានគ្រួសារក្រីក្រ

**ជំហាន ៧ :** ការថតរូបគ្រួសារក្រីក្រ ( អនុវត្តដោយអង្គការមិនមែនរដ្ឋាភិបាលដែលមានកិច្ចសន្យា)

**Step 1:** Establish and train the Planning and Budgeting Committee Representative Group (PBCRG) at the commune level

**Step 2:** Establish and train Village Representative Groups (VRGs)

**Step 3:** VRG compiles List of Households in the Village, conducts household interviews, compiles the First Draft List of Poor Households in the village

**Step 4:** VRG conducts Village Consultation Meeting on First Draft List of Poor Households, receives villager complaints, prepares and displays Final Draft List of Poor Households

**Step 5:** Commune Council reviews and approves Final List of Poor Households, and distributes Equity Cards to poor households (after data entry and photography in Steps 6 and 7)

**Step 6:** Provincial Department of Planning enters all data and household photos into Database of Poor Households

**Step 7:** Photography of poor households (conducted by contracted NGOs)

ដំណើរការខាងលើមានការចូលរួម និងពិគ្រោះយោបល់រវាងអ្នកភូមិ : អ្នកភូមិបោះឆ្នោតជ្រើសរើសក្រុមតំណាងភូមិ ដែលអ្នកភូមិមួយចំនួនបានក្លាយជាសមាជិកក្រុមតំណាងភូមិពួកគេត្រូវផ្តល់បទសម្ភាសន៍ ។ អ្នកភូមិចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ក្នុងភូមិ ស្តីពីបញ្ជីព្រាងគ្រួសារក្រីក្រលើកដំបូង ដើម្បីលើកនូវសំណូមពរ ឬមតិជំទាស់ដែលពាក់ព័ន្ធទៅនឹងបញ្ជីព្រាងគ្រួសារក្រីក្រលើកដំបូង និងបញ្ជីព្រាងគ្រួសារក្រីក្រចុងក្រោយ ។

សមិទ្ធិផលសំខាន់នៃដំណើរការនៅថ្នាក់ឃុំ និងភូមិ គឺបញ្ជីគ្រួសារក្រីក្រចុងក្រោយក្នុងភូមិនីមួយៗ ។

The above process involves substantial villager participation and consultation: they elect the Village Representative Group, some villagers become members of the Village Representative Group, they are respondents in interviews, they take part in a Village Consultation Meeting to discuss the First Draft List of Poor Households, and they can make suggestions or objections relating to the composition of the first and final draft List of Poor Households.

The key output of the process at the commune and village level is a Final List of Poor Households in each village.



ម្យ៉ាងទៀត អាស្រ័យលើតម្រូវការជាក់ស្តែង គ្រួសារដែលបានកំណត់ថាជាគ្រួសារក្រីក្រ គឺអាចទទួលបានប័ណ្ណសមធម៌។ ប័ណ្ណនេះ ១) បង្ហាញឱ្យគ្រួសារក្រីក្រដឹងថា ពួកគាត់អាចស្វែងរកសេវា ឬជំនួយផ្សេងៗដែលពួកគាត់មានសិទ្ធិនឹងទទួល ២) ជួយសម្រួលដល់អ្នកផ្តល់សេវា ក្នុងការពិនិត្យមើលពីអត្តសញ្ញាណនៃសមាជិកគ្រួសារក្រីក្របានឆាប់រហ័ស ដើម្បីផ្តល់សេវាដល់ពួកគាត់ ។

បញ្ជីគ្រួសារក្រីក្រ ត្រូវបានធ្វើបច្ចុប្បន្នភាពពីរឆ្នាំម្តង ដើម្បីរក្សានូវភាពសុក្រិត។

In addition, depending on requirements, all households identified as poor can be issued with Equity Cards (ECs). These cards help to raise the awareness of poor households that they can seek out services and assistance and assert their eligibility to receive them, and help service providers to quickly verify the identity of poor household members in order to provide services to them.

Lists of Poor Households are **updated every two years** in order to maintain their accuracy.

## បញ្ជីសំណួរ

បច្ចុប្បន្នបញ្ជីសំណួរស្តង់ដារជាតិ ត្រូវបានប្រើប្រាស់នូវគ្រប់តំបន់ដែលអនុវត្តដោយក្រសួងផែនការ ឬអង្គការដៃគូ ដើម្បីសម្រេចឱ្យបាននូវលទ្ធផលមួយ ដែលអាចប្រៀបធៀបគ្នាបានក្នុងចំណោមគ្រួសារ និងតំបន់ភូមិសាស្ត្រផ្សេងគ្នា (ភូមិ ឃុំ ស្រុក ខេត្ត)។ បញ្ជីសំណួរនេះផ្ទុំនូវសូចនាករសាមញ្ញមួយចំនួន ដែលក្រុមការងារថ្នាក់ជាតិស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ បានឯកភាពគ្នាទទួលស្គាល់ថាអាចវាស់វែងភាពក្រីក្របានសមស្រប។ សូចនាករទាំងនោះ ផ្អែកជាសំខាន់ទៅលើទ្រព្យសម្បត្តិដែលអាចសង្កេតមើលឃើញ និងងាយផ្ទៀងផ្ទាត់បាន ប៉ុន្តែក៏រួមបញ្ចូលផងដែរនូវបញ្ហាដទៃទៀតដូចជា សមាមាត្រសមាជិកគ្រួសារដែលមិនអាចរកចំណូល ការខកខានរៀន វិបត្តិឬបញ្ហាចៃដន្យ និងស្ថានភាពពិសេសផ្សេងទៀត។ ការសម្ភាសន៍ត្រូវបានធ្វើដោយក្រុមតំណាងភូមិ ដែលមានការយល់ដឹងច្បាស់លាស់ពីស្ថានភាពនៅមូលដ្ឋាន ដែលធ្វើឱ្យងាយស្រួលបញ្ជាក់ថា អ្នកផ្តល់ចម្លើយបានឆ្លើយត្រឹមត្រូវស្របតាមស្ថានភាពជាក់ស្តែងរបស់ពួកគាត់ដែរឬទេ។ ម្យ៉ាងទៀត សមាជិកក្រុមតំណាងភូមិអាចដឹងអំពីស្ថានភាពពិសេសរបស់គ្រួសារ ដែលរស់នៅក្នុងភូមិរបស់គាត់។

ចំពោះព័ត៌មានលម្អិតអំពីបញ្ជីសំណួរ សូមមើលវែបសាយរបស់កម្មវិធី។

## Questionnaire

Currently, a standard questionnaire is used in all areas, regardless of whether the process is carried out by the Ministry of Planning or by partner organisations, in order to optimise comparability of the results of identification among households and among geographical regions (village, commune, district, province). The questionnaire consists of a set of commonsense proxy indicators for poverty, agreed by the national Working Group on Identification of Poor Households, which are mainly based on easily observable and verifiable assets, but also include a number of other issues such as dependency ratio, school attendance, crises or shocks, and other special circumstances. Interviews are conducted by Village Representative Group (VRG) members themselves, whose local knowledge makes it easier to verify whether respondents are accurately reporting their situation, as well as to assess the special circumstances of households.

For more detail about the questionnaire, please see the programme webpage.



## ចំណាត់ថ្នាក់ភាពក្រីក្រ

មានចំណាត់ថ្នាក់ភាពក្រីក្រពីរ សម្រាប់សម្គាល់គ្រួសារក្រីក្រ : ក្រកម្រិតទី១ (ក្រីក្របំផុត) ឬក្រកម្រិតទី២ (ក្រីក្រ)។ ចំណាត់ថ្នាក់ភាពក្រីក្រទាំងពីរនេះ ត្រូវបានកំណត់ដោយផ្អែកលើពិន្ទុក្នុងបញ្ជីសំណួរ (ដោយយោងតាមចន្លោះពិន្ទុដែលបានកំណត់) និងការពិចារណាលើស្ថានភាពពិសេសរបស់គ្រួសារនោះ។ ជាមធ្យមមានប្រហែលមួយភាគបីនៃគ្រួសារសរុប ត្រូវបានដាក់ក្នុងចំណាត់ថ្នាក់ក្រកម្រិត១ ឬ ក្រកម្រិត២។

## Poverty Categories

There are two poverty categories to which poor households can be assigned: Poor Level 1 (very poor) or Poor Level 2 (poor). These poverty categories are assigned based on the questionnaire scores (according to specific cut-off points) and consideration of the special circumstances of households. On average, about one-third of all households are classified as Poor Level 1 or 2.

## ចំណុចខ្លាំង នៃនីតិវិធី

កម្មវិធីផ្តោតជាសំខាន់ទៅលើការប្រើប្រាស់នីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រស្តង់ដារជាតិ ដែលសង្កត់ធ្ងន់ទៅលើការអនុវត្តដោយរចនាសម្ព័ន្ធរដ្ឋាភិបាល និងតំណាងភូមិ ដើម្បីកសាងសមត្ថភាពនៅមូលដ្ឋាន និងជំរុញការអនុវត្តឱ្យមាននិរន្តរភាព។ នីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ មានការចូលរួមយ៉ាងខ្លាំងក្លាដោយអ្នកភូមិក៏ដូចជាការពិគ្រោះយោបល់រវាងអ្នកភូមិផ្ទាល់។ ការចូលរួមនេះបង្កើនតម្លាភាព និងភាពត្រឹមត្រូវនៃលទ្ធផលដែលធ្វើឱ្យអ្នកមូលដ្ឋាន និងអ្នកប្រើប្រាស់ទិន្នន័យងាយទទួលស្គាល់លទ្ធផល។

ផលវិជ្ជមានប្រយោលនៃដំណើរការនេះ គឺជាការពង្រឹងនូវលិទ្ធិប្រជាធិបតេយ្យក្នុងសហគមន៍ដូចជា បង្កើននូវការគិតគូររបស់អ្នកដឹកនាំមូលដ្ឋានអំពីសុខមាលភាពប្រជាពលរដ្ឋ និងកម្រិតនៃគណនេយ្យភាពចំពោះប្រជាពលរដ្ឋ ការចូលរួមរបស់ប្រជាពលរដ្ឋយ៉ាងសកម្មក្នុងកិច្ចការសហគមន៍ និងបង្កើនការពិគ្រោះយោបល់ និងតម្លាភាពក្នុងការធ្វើសេចក្តីសម្រេចចិត្ត។

## Strengths of the Approach

A key emphasis of the IDPoor Programme has been to use identification procedures that maximise implementation by government structures and village representatives, in order to build local capacity and enhance sustainability. The procedures also involve a high degree of participation by and consultation with villagers themselves. This increases the transparency of the process and the accuracy of the results, and therefore the acceptability to local people and to data users.

A positive likely side-effect of this process is the strengthening of democratic values in communities, such as raising local leaders' level of concern about the welfare of their constituents and their degree of accountability to them; active public involvement in community affairs; and enhancing the level of consultation and the transparency of decision-making.



# ទិន្នន័យមូលដ្ឋានគ្រួសារក្រីក្រ

ទិន្នន័យមូលដ្ឋានគ្រួសារក្រីក្រ ត្រូវបានរៀបចំដើម្បីគាំទ្រការអនុវត្តនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងផលិតទិន្នន័យសម្រាប់អ្នកផ្តល់សេវា។ ទិន្នន័យមូលដ្ឋាននេះត្រូវបានរៀបចំនៅកម្ពុជា ហើយអាចប្រើបានជាពីរភាសា (ភាសាខ្មែរ និងអង់គ្លេស)។ ទិន្នន័យមូលដ្ឋានត្រូវបានរៀបចំជាទម្រង់មួយ ដែលអនុញ្ញាតឱ្យមានការបញ្ចូលទិន្នន័យនៅតំបន់ផ្សេងៗគ្នាបាន បន្ទាប់មកអាចផ្តុំទិន្នន័យទាំងនោះនៅថ្នាក់ជាតិ។ នៅក្នុងតំបន់ដែលគ្របដណ្តប់ដោយក្រសួងផែនការ មានមន្ទីរផែនការខេត្តទទួលខុសត្រូវបញ្ចូលទិន្នន័យ។ ក្រសួងផែនការ ក៏ផ្តល់ទិន្នន័យមូលដ្ឋានដល់អង្គការដៃគូ ដើម្បីបញ្ចូលទិន្នន័យសម្រាប់តំបន់ដែលអង្គការដៃគូទាំងនោះគ្របដណ្តប់។ ក្រសួងផែនការ ផ្តុំទិន្នន័យដែលបានមកពីតំបន់ដែលគ្របដណ្តប់ដោយក្រសួងផែនការក៏ដូចជាអង្គការដៃគូ ហើយចែកចាយទិន្នន័យនេះដល់អ្នកផ្តល់សេវា ដើម្បីធ្វើឱ្យមានប្រសិទ្ធភាពខ្ពស់ក្នុងការប្រមូលទិន្នន័យធៀបនឹងការចំណាយ។

# Database of Poor Households

A Database of Poor Households has been developed to support the implementation of identification of poor households, and to generate data for dissemination to service providers. This database was developed in Cambodia and is bilingual (Khmer and English). The database is designed so that data entry can be conducted on a distributed basis in different locations, and then consolidated at the national level. In areas covered by the MOP, the Provincial Departments of Planning do the data entry. The MOP also makes the database freely available to partner organisations to enable them to enter data from their own coverage areas. The intention is to consolidate data from areas covered by the MOP as well as by partner organisations, and make this data available to all interested service providers, in order to maximise the cost-effectiveness of data collection.

# ប្រភេទទិន្នន័យដែលមាន

កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រអាចផ្តល់នូវទិន្នន័យច្រើនប្រភេទសម្រាប់ស្ថាប័នរដ្ឋាភិបាល អង្គការ មិនមែនរដ្ឋាភិបាល កម្មវិធី និងគម្រោងតាមវិស័យ និងសប្បុរសជន ដើម្បីប្រើប្រាស់សម្រាប់ផ្តល់សេវា និងជំនួយដល់គ្រួសារក្រីក្រប្រកបដោយប្រសិទ្ធភាព។ ប្រភេទទិន្នន័យទាំងនេះមានដូចជា : ចំណាត់ថ្នាក់ភាពក្រីក្រនៃគ្រួសារក្រីក្រទាំងអស់ ព័ត៌មានលម្អិតពីសមាជិកគ្រួសារក្រីក្រទាំងអស់ (ឈ្មោះ ភេទ អាយុ ឆ្នាំកំណើត ទំនាក់ទំនងជាមួយមេគ្រួសារ) រូបថតគ្រួសារក្រីក្រ អត្រាប្រៀបធៀបភាពក្រីក្រ រវាងភូមិនិងឃុំ និងស្ថិតិដទៃទៀត។ កម្មវិធីនេះ ក៏អាចផ្តល់ផងដែរនូវទិន្នន័យមូលដ្ឋានទាំងមូលសម្រាប់តំបន់ជាក់លាក់ណាមួយដល់អ្នកប្រើប្រាស់ ដើម្បីស្រាវជ្រាវរកទិន្នន័យដែលត្រូវការដោយខ្លួនឯង។

# What kind of data is available?

The Identification of Poor Households Programme can provide various data reports for use by government institutions, non-governmental organisations, sector programmes and projects, and charities, to target services and development assistance to the poor more effectively. These include the poverty category of all poor households, details of all members of poor households (name, sex, age, year of birth, relationship to head of household), photos of poor households, poverty rate comparisons between villages and communes, and other summary statistics. The Programme can also provide copies of the full database for a specific area, for data users to search for data by themselves.



# ទស្សនៈវិស័យ

បច្ចុប្បន្ន ធនធានរបស់ក្រសួងផែនការនៅមានកម្រិត ដូច្នេះក្រសួងមានលទ្ធភាពអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រ នៅក្នុងតំបន់គោលដៅមួយចំនួនក្នុងប្រទេសតែប៉ុណ្ណោះ។ អាស្រ័យហេតុនេះ ក្រសួងផែនការកំពុងសហប្រតិបត្តិការជាមួយអង្គការដៃគូ ដើម្បីគ្របដណ្តប់តំបន់ផ្សេងទៀត ជាពិសេសផ្តោតលើតំបន់ដែលមូលនិធិសមធម៌សុខភាពកំពុងដំណើរការ។

ក្រសួងផែនការមានទិសដៅអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅក្នុងតំបន់ជនបទទូទាំងប្រទេសកម្ពុជា និងធ្វើបច្ចុប្បន្នភាព បញ្ជីគ្រួសារក្រីក្រជាប្រចាំ ប៉ុន្តែដើម្បីសម្រេចឱ្យបាននៅទិសដៅនេះ ក្រសួងផែនការត្រូវមានធនធានបន្ថែមទៀត។ ការបង្កើតកញ្ចប់ថវិកាជំនួយរួមនឹងផ្តល់លទ្ធភាពអោយរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា រួមចំណែកក្នុងការផ្តល់ថវិកាសម្រាប់គាំទ្រកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។

គោលបំណងសំខាន់មួយទៀតរបស់ក្រសួងផែនការ គឺសហការឱ្យបានជិតស្និទ្ធជាមួយក្រសួងមហាផ្ទៃ ដើម្បីសម្រេចឱ្យបាននូវការធ្វើសមាហរណកម្មអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ទៅក្នុងក្របខ័ណ្ឌការងារក្រុមប្រឹក្សាឃុំ និងរចនាសម្ព័ន្ធគាំទ្រក្រុមប្រឹក្សាឃុំ។ ការធ្វើសមាហរណកម្មនេះ នឹងជំរុញនិរន្តរភាពរយៈពេលវែងនៃអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងការប្រើប្រាស់ទិន្នន័យគ្រួសារក្រីក្រទូលំទូលាយដោយក្រុមប្រឹក្សាឃុំ សម្រាប់ជាឧបករណ៍មួយសម្រាប់ការកសាងផែនការអភិវឌ្ឍន៍ឃុំ ។

ការងារសំខាន់មួយទៀត គឺជំរុញការប្រើប្រាស់ទូលំទូលាយនូវទិន្នន័យដោយស្ថាប័នរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល កម្មវិធី និងគម្រោងតាមវិស័យ និងសប្បុរសជន ក៏ដូចជាក្រុមប្រឹក្សាឃុំ ជាឧបករណ៍សម្រាប់ផ្តល់សេវា និងជំនួយដល់គ្រួសារក្រីក្រ។ កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៃក្រសួងផែនការ បាននិងកំពុងធ្វើការផ្សព្វផ្សាយនៅថ្នាក់ស្រុក ខេត្ត និងជាតិ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីកម្មវិធី និងដើម្បីផ្សព្វផ្សាយទិន្នន័យ។

# Looking ahead

Currently, the MOP has limited resources and can therefore only conduct identification of poor households in selected areas of the country. Therefore, the MOP is cooperating with partner organisations in order to cover as many areas as possible.

The MOP aims to expand identification of poor households to cover all rural areas nationwide as soon as possible, and to carry out regular updates. However, in order to do this, the MOP will require additional resources. The planned creation of a pooled funding mechanism will enable the government and various development partners to contribute to and share the costs of identification.

Another key objective of the MOP is to work closely with the Ministry of Interior to achieve the **integration of identification of poor households as a routine task of Commune Councils** and their support structures. Institutionalisation of the programme within these structures will promote its long-term sustainability, and the widespread use of data on poor households by commune councils as a tool for commune planning.

Another key task is to further promote widespread use of the collected data by government institutions, non-governmental organisations, and sector programmes and projects, and charities, as well as Commune Councils, as a tool for targeting services and assistance to poor households. The MOP Identification of Poor Households Programme is carrying out promotional activities at district, provincial and national levels to raise awareness about the programme and to disseminate data.

# ទំនាក់ទំនង

ប្រសិនបើចង់ដឹងព័ត៌មានបន្ថែមអំពីកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ សូមទាក់ទង :


**កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ**
**នាយកដ្ឋានផែនការសង្គមកិច្ច នៃក្រសួងផែនការ**

ទូរស័ព្ទ: (០២៣) ២២០ ៧៤០

អ៊ីមែល: idpoor@online.com.kh

វែបសាយ: www.mop.gov.kh/ProgramsProjects/IDPoor/tabid/154/Default.aspx


# Contact details

If you are interested in finding out more about the MOP Identification of Poor Households Programme, please contact:


**Identification of Poor Households Programme**
**Social Planning Department**
**Ministry of Planning**

Tel: (023) 220 740

Email: idpoor@online.com.kh

Webpage: www.mop.gov.kh/ProgramsProjects/IDPoor/tabid/154/Default.aspx



**This programme is supported by the Federal Republic of Germany**

German-Cambodian Cooperation

German Technical Cooperation